ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ៥៨ ត្រីមាសទី ០៣ ឆ្នាំ ២០១៧

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

# ក

# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម

២៩-០៧-២០១៧ -ព្រះរាជក្រម នស/រកម/០៧១៧/០០៨ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនអាឡិច ខបភើរេសិន ៥៩៧៨

### ២-ព្រះរាជក្រឹត្យ

២៩-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៨៦ ស្តីពី ការកែសម្រួលមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា ៤ ថ្មី, មាត្រា ១០ ថ្មី, មាត្រា ១១ ថ្មី, មាត្រា ១២ ថ្មី និងមាត្រា ២០ ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពី ការកែសម្រួលមាត្រា ៤ មាត្រា ១០ មាត្រា ១១ មាត្រា ១២ មាត្រា ១៤ មាត្រា ១៧ និងមាត្រា ២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតរាជបណ្ឌិត្យ សភាកម្ពុជា ៥៩៩៤

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ២៧ និងមាត្រា ៣៤ នៃអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពី ការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្ម ទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៥៩៩៨

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ១១៩ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦០០៣

២៨-០៧-២០១៧ -អនុក្រឹត្យលេខ ១២០ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦០០៥

២៨-០៧-២០១៧ -អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦០០៧

១១-០៧-២០១៧ -អនុក្រឹត្យលេខ ៧០៥ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស សុវត្ថារា និង មុនីសារាភ័ណ្ឌ ៦០០៩

២៧-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦០១៣

២៧-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦០៥១

## ២_សេចក្តីសម្រេច

២៨-០៧-២០១៧ -សេចក្តីសម្រេចលេខ ៥៧ សសរ ស្តីពី ការតែងតាំងសមាសភាពនៃលេខាធិការដ្ឋាន ជាតិអាស៊ាន កម្ពុជា ៦០៥៤

២៨-០៧-២០១៧ -សេចក្តីសម្រេចលេខ ៥៨ សសរ ស្តីពី ការប្រកាសកាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើស តាំងសមាជិកព្រឹទ្ធសភា សម្រាប់នីតិកាលទី ៤ នៃព្រឹទ្ធសភា ៦០៥៧

## III_ការងារបណ្តាក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

០៨-០៥-២០១៧ -ប្រកាសលេខ ១៩០ ឧស.កឧ.ប្រក ០៥ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេម វើណា ហ្វេសិន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៦០៥៩

០៨-០៥-២០១៧ -ប្រកាសលេខ ១៩១ ឧស.កឧ.ប្រក ០៥ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ណាន់ គង់ ហ្គាមិន (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៦០៦២

០៨-០៥-២០១៧ -ប្រកាសលេខ ១៩២ ឧស.កឧ.ប្រក ០៥ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ុកម៉ា ថេកស្តាយ (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ កម្រាលតុ កម្រាលពូក និងស្រោមខ្នើយ ៦០៦៥

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

០៦-០៦-២០១៧ -ប្រកាសលេខ ១៤៦៩ ប្រក ស្តីពី បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ៦០៦៨

០៦-០៦-២០១៧ -ប្រកាសលេខ ១៤៧៧ ប្រក ស្តីពី បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ៦០៧៥

## ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

០៧-០៧-២០១៧ -ប្រកាសលេខ ៣៧៨ ប្រក.កសក ស្តីពី ស្លាកសញ្ញាព័ត៌មានបញ្ជាក់លើសំបកវេចខ្ចប់ ពូជដំណាំ ៦០៨២

# ព្រះរាជក្រម

នស/រកម/០៧១៧/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន អាឡិច ឧបតើរេសិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុន អាឡិច ឧបតើរសេិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងរ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឲ្យក្រុមហ៊ុន អាឡិច ឧបតើរសេិន ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន អាឡិចឧបតើរសេិន និងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី រវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន អាឡិចឧបតើរសេិន ដែលបានចុះហត្ថលេខា នៅរាជធានីភ្នំពេញ នាថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៧ ។ ការធានានេះ មានអត្ថបទទាំងស្រុង ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៧ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៧

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសបន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

នស/រកម/០៧១៧/០១៥

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**អូន ព័ន្ធមុនីរ័ត្ន**

លេខ ១៥៥៤ ស.ណ

**សំណៅដែលមានបម្រុងជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៧០ សរ/ប.ក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១៧

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសម្បទាន
- បានឃើញអនុក្រឹត្យ លេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការសម្រេចរបស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង IMPLEMENTATION AGREEMENT (IA) និងលើលិខិតធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (GOVERNMENTAL GUARANTEE OF PAYMENT) ដោយអគ្គិសនីកម្ពុជា (អក) និង/ឬ ក្រសួងរ៉ែនិងថាមពល (ក្ររ៉ថ) ទៅឱ្យក្រុមហ៊ុន ALEX CORPORATION សម្រាប់គម្រោងប្រព័ន្ធបញ្ជូនអគ្គិសនី ២៣០ គីឡូវ៉ុល ពីស្ថានីយរ៉ាវីអគ្គិសនីស្ទឹងតាតៃ មក ភ្នំពេញ។

ក្នុងករណីដែលឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោម លើសិទ្ធិប្រទាននេះ។

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

រាជរដ្ឋាភិបាល

*Royal Government*

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion King*

Nº 20 D.F.P

Phnom Penh, March 06, 2017

# DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0913/903 dated 24 September 2013 on the nomination of the Royal Government of Cambodia
- Seen the Royal Kram 02/NS/94 dated 20 July 1994 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/0196/18 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Seen the Royal Kram NS/RKM/1216/019 dated 14 December 2016 promulgating the Law on Finance for Management of the Year 2017
- Seen the Royal Kram 03/NS/94 dated 05 August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 March 2003
- Seen the Royal Kram NS/RKM/1007/027 dated 19 October 2007 promulgating the Law on Concessions
- Seen Sub-decree 111 អនក្រ.បក dated 27 September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia
- Referring to the decision of Council of Ministers in its plenary session on 17 February 2017.

**THE ROYAL GOVERNMENT OF CAMBODIA**

Delegates herewith to H.E. DR. AUN PORNMONIROTH, Senior Minister, Minister of Economy and Finance, full power to sign the Implementation Agreement (IA), and the Governmental Guarantee of Payment by the EDC and/or MME to ALEX CORPORATION for the 230 kV Stung Tatay Hydro Power Plant - Phnom Penh Transmission System Project.

These powers include the powers of delegation.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

**Prime Minister**

**Samdech Akka Moha Sena Padei Techo HUN SEN**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០១ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ ៧ ឆ្នាំ ២០១៧

# លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

**ជូនចំពោះ** : **លោក** LAU YAO ZHONG
**អាឡិច ខបភើរេសិន** (ALEX CORPORATION)

**អាសយដ្ឋាន** : លេខ ៤៤៥, អគារភ្នំពេញ, ជាន់ទី១៣A, ចំណុចប្រសព្វមហាវិថីព្រះមុនីវង្ស និងផ្លូវលេខ ២៣២, សង្កាត់បឹងព្រលិត, ខណ្ឌ៧មករា, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

**ទូរសារ** : (៨៥៥) ២៣ ៨៦៦ ៦៦៦

**យោង** :

(ក) លិខិតប្រទានលេខ ២០ សប្រទ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (ឧបសម្ព័ន្ធ១)។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ដែលបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយរដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល (ក្ររ៉ថ) និងក្រុមហ៊ុន អាឡិច ខបភើរេសិន (Alex Corporation) (ក្រុមហ៊ុន)។

(គ) អគ្គិសនីកម្ពុជា ជាសហគ្រាសរដ្ឋ មានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់ (អ.ក), បានចុះកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី (PTA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧។

(ឃ) រាជរដ្ឋាភិបាលកម្ពុជាយល់ព្រមផ្តល់ : (១)-ការធានាលើការទូទាត់ថ្លៃបញ្ជូនអគ្គិសនី សម្រាប់ការប្រើប្រាស់គម្រោង ១០០% (មួយរយភាគរយ) ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាមកិច្ចព្រមព្រៀង PTA និង/ឬ IA ក្នុងករណីដែលក្រុមហ៊ុនមិនអាចដំណើរការគម្រោងបាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ប្រធានសក្តិនយោបាយ។

(ង) តាមការតម្រូវក្នុងប្រការ ៤.៨ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (សហវ) ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (អ្នកធានា) បានយល់ព្រមចុះហត្ថលេខា លើលិខិតធានាលើការទូទាត់ ដែលជាកាតព្វកិច្ចរបស់ អ.ក ឬ ក្រវ៉ាថ ស្របតាម PTA និង IA។

**ដូច្នេះ យើងខ្ញុំសូមធានា ថា :**

១. អ្នកធានាសូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុននូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ក្រវ៉ាថ ឬ អ.ក ឱ្យក្រុមហ៊ុនក្រោមកិច្ចព្រមព្រៀង IA ឬ PTA ដែល ក្រវ៉ាថ ឬ អ.ក ខកខានពុំបានទូទាត់ អនុលោមតាមអាណត្តិនៃ IA ឬ PTA។

២. លិខិតធានានេះ ត្រូវជាការធានាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ដែលត្រូវបង់ឱ្យក្រុមហ៊ុនគ្រប់ពេល ដោយ ក្រវ៉ាថ ឬ អ.ក ក្រោមកិច្ចព្រមព្រៀង IA ឬ PTA ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ឬការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ក្រវ៉ាថ ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ក្រវ៉ាថ ឬ អ.ក។ ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ១១.១ នៃ PTA ឬសំណើសុំទូទាត់ណាមួយពីក្រុមហ៊ុន ទៅ ក្រវ៉ាថ ត្រូវបានទទួលដោយ អ.ក ឬ ក្រវ៉ាថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ ដោយ ក្រវ៉ាថ ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើការទូទាត់ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់របស់អ្នកធានា ក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ)។ ពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុន ស្របតាមលិខិតធានានេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិ របស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយបត្រ ដែលមិនទាន់ទូទាត់ផ្សេងទៀតឡើយ។

ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំណត់ដោយក្រុមហ៊ុន ជាប្រាក់ដុល្លារអាមេរិកឱ្យក្រុមហ៊ុន។

៤. រាល់សំណើសុំទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត បញ្ជាក់ថា:

"យើងខ្ញុំ សូមបញ្ជាក់ថា:

(១). ក្រុមហ៊ុន អាឡិច ខបភើរេសិន (ក្រុមហ៊ុន) បានធ្វើសំណើសុំទូទាត់ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់........ {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី...... ខែ....... ឆ្នាំ២០១៧ រវាង អ្នកធានា និងក្រុមហ៊ុន។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់កាលកំណត់ និងត្រូវទូទាត់ដោយ អ.ក ឬ គ្រវ៉ថ ស្របតាម PTA/IA រវាងក្រុមហ៊ុន និង អ.ក ឬ គ្រវ៉ថ និងពុំមានផ្នែកណាមួយ នៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក ឬ គ្រវ៉ថ និង ក្រុមហ៊ុននោះទេ។

(៣). សំណើសុំទូទាត់ពី គ្រវ៉ថ ឬ អ.ក ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ គ្រវ៉ថ ឬ អ.ក រហូតដល់ថ្ងៃនេះ។

៥. អ្នកធានាសូមអះអាង និងធានា នៅថ្ងៃនេះថា:

អ្នកធានាមានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា ការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ។

លិខិតធានានេះ ជាកាតព្វកិច្ចរបស់អ្នកធានាស្របច្បាប់ មានសុពលភាព ប្រសិទ្ធភាព និងជាចំណងផ្លូវច្បាប់ អនុលោមតាមអាណត្តិ របស់លិខិតធានានេះ។

រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រមដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ។

កាតព្វកិច្ច និងការព្រមព្រៀងនានារបស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានា ត្រូវបានប្រកាន់ខ្ជាប់។

អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថាការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ គឺជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។

ប្រសិនបើមានបណ្តឹងណាមួយ ចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទសាងសង់ (Construction Commencement Date) រហូតដល់ចប់អាណត្តិ នៃ IA ឬ PTA និងត្រូវបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ណាមួយ ដែល អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនេះ ឬនៅពុំទាន់ទូទាត់។ រីឯការធានាលើការទូទាត់លើថ្លៃបញ្ជូនអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់សម្រាប់ការប្រើប្រាស់សមត្ថភាពគម្រោង ត្រូវមានសុពលភាពចាប់ពីថ្ងៃដែលគម្រោងដំណើរការអាជីវកម្ម (Commercial Operation Date)។

៧. គ្មានការខកខាន ឬការយឺតយ៉ាវណាមួយដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយក្រោមលិខិតធានានេះ ត្រូវបានចាត់ទុកជាការបោះបង់សិទ្ធិ ឬការដោះស្រាយនោះឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក រារាំងការអនុវត្តបន្ថែម នូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ។ គ្មានការបដិសេធណាមួយរបស់ក្រុមហ៊ុន មានប្រសិទ្ធភាពទេ លើកលែងតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ។

សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលត្រូវបានផ្តល់ដោយច្បាប់ឡើយ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា “លិខិតជូនដំណឹង”) ដែលត្រូវផ្តល់ ឬធ្វើឡើងស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវដាក់អាសយដ្ឋានបញ្ជូនទៅបុគ្គល ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមអ្នករត់សំបុត្រ។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថា បានប្រគល់ :

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅថ្ងៃប្រគល់ ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួលដោយអ្នកផ្ញើឯកសារ ដែលមានការទទួលស្គាល់ជាអន្តរជាតិ បញ្ជូនទៅភាគីទទួល នៅអាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹងឱ្យទៅភាគីប្រគល់លិខិត នៅអាសយដ្ឋាន ឬលេខទូរសារ ចែងខាងក្រោម) :

សម្រាប់អ្នកធានា :

| | | |
|---|---|---|
| ជូនចំពោះ | : | ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| អាសយដ្ឋាន | : | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ផ្លូវលេខ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ,<br>រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា |
| ទូរសារលេខ | : | +៨៥៥ ២៣ ៤២៧ ៧៩៨ |

សម្រាប់ក្រុមហ៊ុន :

| | | |
|---|---|---|
| អាសយដ្ឋាន | : | លេខ ៤៤៥, អគារភ្នំពេញ, ជាន់ទី១៣A,<br>ចំណុចប្រសព្វមហាវិថីព្រះមុនីវង្ស និងផ្លូវលេខ ២៣២,<br>សង្កាត់បឹងព្រលិត, ខណ្ឌ៧មករា,<br>រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា |
| ទូរសារ | : | ៨៥៥ ២៣ ៨៦៦ ៦៦៦ |
| ជូនចំពោះ | : | ប្រធានក្រុមហ៊ុន |

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកធានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីអ្នកធានាឡើយ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬការផ្តល់ហិរញ្ញប្បទានអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់។ លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាពជាប្រយោជន៍ដល់អ្នកធានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់ របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកធានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតធានានេះ ត្រូវបាន គ្រប់គ្រងដោយ និងបកស្រាយ តាមច្បាប់នៃប្រទេសអង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រង មជ្ឈត្តវិនិច្ឆ័យផងដែរ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹង លិខិតធានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយ បានទទួលសេចក្តីជូនដំណឹង ពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកធានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈការពិភាក្សាជាមិត្តភាព ទេ ត្រូវបញ្ជូនវិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយ ស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើមានភាព មិនស្របគ្នាដោយអន្លើ រវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងជាសេចក្តីសម្រេច ស្ថាពរ ជាសេចក្តីសន្និដ្ឋាន និងជាចំណងផ្លូវច្បាប់ទៅលើអ្នកធានា និងក្រុមហ៊ុន និងអាចយកមកអនុវត្ត នៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការ ធ្វើឱ្យសេចក្តីសម្រេចនោះ អនុវត្តបាន។ ភាគីទាំងពីរត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយ ឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយ ដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនោះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយ ទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតធានានេះមានប្រសិទ្ធភាពអនុវត្ត។ រាល់ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវ ទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣% (បីភាគ រយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពី កាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច។

១២. ពាក្យសរសេរជាអក្សរធំ ដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យ ដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ក្នុងលិខិតធានានេះ ត្រូវបានរកឃើញថា គ្មានសុពលភាព ខុសច្បាប់ ឬមិនអាចអនុវត្តបាន បញ្ញត្តិទាំងនោះ ត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មាន សុពលភាព ភាពខុសច្បាប់ ឬភាពមិនអាចអនុវត្តបានទាំងនោះ ពុំមានឥទ្ធិពលដល់សុពលភាព នៃ បញ្ញត្តិផ្សេងទៀត នៃលិខិតធានានេះឡើយ។

តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការកាត់កង ការទាមទារទៅវិញទៅមក ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកធានា ដើម្បីតតាំងជាមួយក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយ របស់អ្នកធានា ចំពោះក្រុមហ៊ុនក្រោមលិខិតធានានេះឡើយ។

១៤. លិខិតធានានេះ ត្រូវផុតសុពលភាពនៅពេលបញ្ចប់ IA និង PTA ប្រសិនបើគ្មានការទាមទារ ហើយនៅរក្សាការធានានេះដដែល ក្នុងករណីមានសំណើសុំការទូទាត់ជាលាយលក្ខណ៍អក្សរណាមួយ ពីលោកបញ្ជូនមកយើងខ្ញុំ ស្របតាមលិខិតធានានេះ ដែលត្រូវតែទទួលបានដោយយើងខ្ញុំ មុនពេលនោះ។

១៥. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោកប្រធានក្រុមហ៊ុន មេត្តាទទួលនូវការរាប់អាន ពីខ្ញុំ។

...មន្ត្រី
...រដ្ឋមន្ត្រី...សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងរ៉ែ និងថាមពល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

№ 001 MEF/...........

Phnom Penh, March 28, 2017

GOVERNMENT GUARANTEE OF PAYMENTS

To : Mr. LAU YAO ZHONG,
ALEX CORPORATION
No. 445, Phnom Penh Tower, 13A Floor,
corner of Preah Monivong Blvd. and Street 232,
Sangkat Boeung Pralit, Khan 7 Makara,
Phnom Penh, Kingdom of Cambodia.
Facsimile : +855 23 866 666

Dear Sir,

We refer to:

(A) Delegation of Full Power No. 20 DFP dated 06th March 2017, by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia. (Attachment 1).

(B) The Implementation Agreement ("IA") dated 15th March 2017, entered between the Royal Government of Cambodia ("RGC") represented by Minister, Ministry of Mines and Energy ("MME") and Alex Corporation (the "Company").

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Wat Phnom, Daun Penh District, Phnom Penh, in the Kingdom of Cambodia, including its successors and permitted assignees ("EDC") has entered into a Power Transmission Agreement ("PTA") with the Company dated 15th March 2017.

(D) The Royal Government of Cambodia agreed to provide: (i) a guarantee on the payment for PTA charges for use of 100% of the Project in the event of non-payment by EDC, and (ii) guarantee on the payment on the termination in accordance with the PTA and/or IA and in the event that the Company is unable to operate the Project arising from the Political Force Majeure Events.

(E) It is a requirement of the Implementation Agreement in accordance with its Section 4.8 of the IA, the Minister of Economy and Finance on behalf of Royal Government of Cambodia (the "Guarantor") has agreed to enter into this Guarantee of the payment obligations of EDC/MME under the PTA and IA.

**We hereby guarantee that**:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay to the Company any and every sum of money which is due and owed by MME or EDC to the Company under the IA or PTA that MME or EDC has failed to pay in accordance with the terms of the IA or PTA.

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MME or EDC under the IA or PTA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MME or EDC. After sixty (60) days from the date of the invoice(s) as specified in Section 11.1 of the PTA or any payment demand from the Company to MME being received by EDC or MME, the Company may notify the Guarantor in writing that payment from MME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within thirty (30) Days. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). And no demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s).

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that:

   "We hereby certify that:

   (1) Alex Corporation (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U.S. Dollars ------------- [insert amount] in accordance with Section 1 of the Guarantee dated ----------------- between the Guarantor and the Company;

   (2) The amount specified above is due and payable by [EDC or MME] under the PTA/IA between the Company and EDC/MME and no part of the amount specified above is the subject of a dispute between the EDC/MME and the Company;

   (3) Demand in writing for payment from MME/EDC has been made;

   (4) Such amount, on the date hereof, remains unpaid by MME/EDC."

5. The Guarantor represents and warrants that, as of the date hereof:

   The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.

This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.

All necessary action has been taken, and all approvals required have been obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.

The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.

The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes our unconditional and irrevocable direct obligation.

Should any proceedings be brought against it or its assets in any jurisdiction in relation to this Agreement, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the term of the IA or PTA and for so long thereafter as any amount owed to the Company by EDC in connection with such term is or may be outstanding. However, such Guarantee on PTA charges in the event of non-payment by EDC for the use of capacity of the Project shall be applicable from the Commercial Operation Date (COD) of the Project.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing.

   The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:

   (a) When presented personally, or

   (b) Upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such Party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

   The address for service of Notice shall be:

   For the Guarantor:

| | | |
|---|---|---|
| Attention | : | Minister, Ministry of Economy and Finance |
| Address | : | Ministry of Economy and Finance<br>Street No. 92, Sangkat Wat Phnom, Khan Daun Penh,<br>Phnom Penh, Kingdom of Cambodia |
| Facsimile | : | +855 23 427 798 |

For the Company:

| | | |
|---|---|---|
| Address | : | No. 445, Phnom Penh Tower, 13A Floor, corner of<br>Preah Monivong Blvd. and Street 232, Sangkat Boeung<br>Pralit, Khan 7 Makara, Phnom Penh,<br>Kingdom of Cambodia. |
| Fax No. | : | +855 23 866 666 |
| Attention | : | The President |

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee shall be governed by and construed according to the Laws of England, which shall also be the procedural law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute can't be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Transmission Agreement.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee.
Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14. This Guarantee shall expire upon the termination of the IA and PTA if no claim has been made and remains outstanding hereunder and any written demand made to us by you hereunder must therefore be received by us before that time.

15. This Guarantee shall become in full and effective on its ratification by legislatures of the Kingdom of Cambodia.

Yours faithfully,

DR. AUN PORNMONIROTH
SENIOR MINISTER,
MINISTER OF ECONOMY AND FINANCE

CC :
- Ministry of the Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Council for the Development of Cambodia (CDC)
- Office of Council of Ministers
- Ministry of Foreign Affairs and International Cooperation
- Ministry of Industry, Mines, and Energy
- Cabinet of Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia
- Electricite du Cambodge (EDC)
- File

## ព្រះរាជក្រឹត្យ

នស/រកត/០៣១៧/៥៥៦

## ស្ដីពី

## ការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

មាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ត្រូវបានកែសម្រួល ដូចតទៅ៖

**មាត្រា៤ ថ្មី (មួយ).-**

មាត្រា ៤ ថ្មី កថាខណ្ឌទី១ វាក្យខណ្ឌទី២ ត្រូវបានកែសម្រួលដូចតទៅ៖

សមាជិកពេញសិទ្ធិ មានចំនួនកំណត់មិនលើសពី ៧៩ រូប។

**មាត្រា៦ ថ្មី.-**

លក្ខណៈជាសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក សមាជិកកិត្តិយស ឬសមាជិកឆ្លើយឆ្លង ត្រូវរលាយបាត់ទៅវិញ ដោយមរណភាព ឬដោយការសុំលាឈប់។

សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា រួមគ្នាបង្កើតក្រុមសមាជិកពេញសិទ្ធិ ដែលហៅថា "ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ"។ ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។

សមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក សមាជិកកិត្តិយស ឬសមាជិកឆ្លើយឆ្លង ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

លក្ខន្តិកៈសមាជិកនៃរាជបណ្ឌិត្យសភាកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០ថ្មី(មួយ).-**

រាជបណ្ឌិត្យសភាកម្ពុជាដឹកនាំដោយប្រធាន ០១(មួយ)រូប និងមានអនុប្រធានយ៉ាងច្រើនចំនួន ០៣(បី)រូបជាជំនួយការ។

ការកិច្ចរបស់ប្រធាន និងអនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា១១ ថ្មី(មួយ).-**

ប្រធាន និងអនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា ហើយត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

**មាត្រា១២ ថ្មី(មួយ).-**

អគ្គលេខាធិការដ្ឋាននៃរាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយអគ្គលេខាធិការ ០១ (មួយ) រូប និងអគ្គលេខាធិការរង យ៉ាងច្រើនចំនួន ០៣(បី) រូប ដើម្បីជួយការងារប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

អគ្គលេខាធិការ ត្រូវមានសញ្ញាបត្របណ្ឌិត និងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ មានឋានៈស្មើ រដ្ឋលេខាធិការ។

អគ្គលេខាធិការរង ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ និងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

ការបែងចែងភារកិច្ចអគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា២០ថ្មី(មួយ).-**

រាជបណ្ឌិត្យសភាកម្ពុជា មានវិទ្យាស្ថាន និងស្ថាប័នឧបសម្ព័ន្ធដូចខាងក្រោម ៖

១- វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ
២- វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម
៣- វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម
៤- វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
៥- វិទ្យាស្ថានភាសាជាតិ
៦- វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា
៧-ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប។

រាជបណ្ឌិត្យសភាកម្ពុជា អាចបង្កើតវិទ្យាស្ថាន និងស្ថាប័នឧបសម្ព័ន្ធផ្សេងទៀតតាមការចាំបាច់ដោយអនុក្រឹត្យ។

**មាត្រាពីរ.-**

ត្រូវរៀបចំផ្ទេរតាមរយៈព្រះរាជក្រឹត្យនូវក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រាបី.-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចដំណើរការរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលកំពុងអនុវត្តត្រូវបន្តអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានថ្មី មកជំនួស។

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាបួន.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៧
**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ចរស.១៧០៧.៥៩៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៥៩៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួល មាត្រា២៧ និងមាត្រា៣៤ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្ម ទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គ-នាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់របនា-សម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**មាត្រាមួយ .-**

មាត្រា២៧ និងមាត្រា៣៤ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មទៅជាអគ្គ-នាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា២៧.- ថ្មី**

អគ្គនាយកដ្ឋានកសិកម្ម មាននាយកដ្ឋានចំណុះចំនួន៩ និងមន្ទីរពិសោធន៍ជាតិកសិកម្មចំនួន១ មានថ្នាក់ស្មើនឹងនាយកដ្ឋានដូចខាងក្រោម៖

១- នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ
២- នាយកដ្ឋានដំណាំស្រូវ
៣- នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ
៤- នាយកដ្ឋានដំណាំឧស្សាហកម្ម
៥- នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ
៦- នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម
៧- នាយកដ្ឋានវិស្វកម្មកសិកម្ម
៨- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
៩- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម
១០- មន្ទីរពិសោធន៍ជាតិកសិកម្ម។

អង្គការលេខរបស់អគ្គនាយកដ្ឋានកសិកម្មត្រូវបានកំណត់ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៣៤ .– ថ្មី**

នាយកដ្ឋានវិស្វកម្មកសិកម្មមានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវ និងកំណត់បែងចែកតំបន់ប្រើប្រាស់គ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្ម ម៉ាស៊ីនកសិកម្មតាមប្រភេទដី និងតាមមុខដំណាំ ដើម្បីអភិវឌ្ឍវិស័យកសិកម្ម
- រៀបចំគោលការណ៍ លិខិតបទដ្ឋានអំពីសក្តានុពល និងអំពីប្រសិទ្ធភាពគ្រឿងយន្តកសិកម្ម ក្នុងផលិតកម្មដាំដុះ
Ministry of Industry & Handicraft

លេខ : ១៩៤ ឧស.ក.ស្រ.ឧក.០៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៧

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ កម្រាលតុ កម្រាលពូក និងស្រោមខ្នើយ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ របស់ ក្រុមហ៊ុន ស៊ិកម៉ា ថេកស្តាយ (ខេមបូឌា)។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ិកម៉ា ថេកស្តាយ (ខេមបូឌា) (SIGMA TEXTILES (CAMBODIA) CO., LTD.) តំណាងដោយ លោក YANG ZUDE បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ កម្រាលតុ កម្រាលពូក និងស្រោមខ្នើយ ដែលមានទីតាំងស្ថិតនៅ អគារF1 ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១.សម្លៀកបំពាក់ | ១៤១០ |
| ២.កម្រាល (តុ ពូក ខ្នើយ) | ១៣៩២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ ៖** " រោងចក្រកាត់ដេរសម្លៀកបំពាក់ កម្រាលគុ កម្រាលពូក និងស្រោមខ្នើយ ស៊ិកម៉ា ថេកស្តាយ (ខេមបូឌា) "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ០២២៥ ឧស.កឧ.ប្រក.៩ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ កម្រាលគុ កម្រាលពូក និងស្រោមខ្នើយ របស់ក្រុមហ៊ុន ស៊ិកម៉ា ថេកស្តាយ (ខេមបូឌា) ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ១៤៦៩ ប្រ.ក

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីប័ណ្ណព្រំដែនកម្ពុជា-ឡាវ
- បានឃើញកិច្ចព្រមព្រៀង ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការឆ្លងកាត់ព្រំដែន
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមសំណើរបស់អគ្គនាយកដ្ឋានរដ្ឋបាល

## សម្រេច

## ជំពូកទី១

## សមត្ថកិច្ចគ្រប់គ្រង និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ

**ប្រការ ១.-**

អភិបាលខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជាជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ត្រូវបានប្រតិភូកម្មអំណាចឲ្យចុះហត្ថលេខាលើប័ណ្ណព្រំដែនកម្ពុជា-ឡាវ ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីផ្តល់ជូនប្រជាពលរដ្ឋខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អភិបាលខេត្តត្រូវដឹកនាំចាត់ចែង និងផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរ ស្របទៅតាមគោលការណ៍ បែបបទ និងនីតិវិធី ដែលបានកំណត់ជាធរមាន។

**ប្រការ ២.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវត្រូវបានផលិត គ្រប់គ្រង ចាត់ចែង និងបែងចែកទៅតាមខេត្តដោយក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ជាសេនាធិការ។

អគ្គនាយកដ្ឋានរដ្ឋបាលជាសេនាធិការឲ្យក្រសួងមហាផ្ទៃនៅក្នុងការរៀបចំទម្រង់បែបបទ និងការផ្តល់ការណែនាំបណ្តុះបណ្តាលមន្ត្រីនៅរដ្ឋបាលខេត្ត ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគ្រប់គ្រងការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ។

អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុជាសេនាធិការឲ្យក្រសួងមហាផ្ទៃនៅក្នុងការផលិត និងរក្សាទុកប័ណ្ណព្រំដែនកម្ពុជា-ឡាវឲ្យបានត្រឹមត្រូវ ដោយមានកិច្ចសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល។

## ជំពូកទី២

## អំពីប័ណ្ណព្រំដែនកម្ពុជា-ឡាវ

**ប្រការ ៣.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវមានពណ៌ខៀវ និងមានចំនួន ៣២ទំព័រ ដែលមានលក្ខណៈសំគាល់របស់សាមីខ្លួនដូចខាងក្រោម៖

- ឈ្មោះ "នាមត្រកូល និងនាមខ្លួន"

- ភេទ
- លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលេខប័ណ្ណបញ្ជាក់ទីលំនៅ ឬលេខសំបុត្រកំណើត ឬលេខសំបុត្របញ្ជាក់កំណើត ឬលេខសៀវភៅគ្រួសារ
- ថ្ងៃខែឆ្នាំកំណើត
- ទីកន្លែងកំណើត
- កម្ពស់
- មុខរបរ
- អាសយដ្ឋាន
- ភិនភាគសំគាល់ពិសេស
- រូបថត
- ហត្ថលេខា ឬស្នាមផ្តិតមេដៃស្តាំ។

ក្នុងប័ណ្ណព្រំដែនកម្ពុជា-ឡាវអាចបញ្ចូលឈ្មោះកូនស្របច្បាប់របស់អ្នកកាន់ប័ណ្ណព្រំដែនបានចំនួន ០២ នាក់ដែលមានអាយុក្រោម ១២ឆ្នាំ ដោយត្រូវកំណត់លក្ខណៈសំគាល់របស់កូនដូចខាងក្រោម៖

- ឈ្មោះ "នាមត្រកូល និងនាមខ្លួន"
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- រូបថត
- លក្ខណៈសំគាល់។

លក្ខណៈសំគាល់ខាងលើនេះ ត្រូវចុះក្នុងប័ណ្ណព្រំដែនកម្ពុជា-ឡាវជាភាសាខ្មែរ និងភាសាអង់គ្លេស។

**ប្រការ ៤.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវមានសុពលភាពរយៈពេល ០១ឆ្នាំ និងអាចបន្តសុពលភាពបានយ៉ាងយូរ ០១ ឆ្នាំ។ ផុតរយៈពេលបន្តសុពលភាពនេះ មិនអាចប្រើប្រាស់បានតទៅទៀតទេ។

**ប្រការ ៥.-**

នៅពេលផុតសុពលភាពប័ណ្ណព្រំដែន សាមីខ្លួនអាចស្នើសុំបន្តសុពលភាពប័ណ្ណព្រំដែនបាន ដោយត្រូវបំពេញពាក្យស្នើសុំ និងភ្ជាប់មកជាមួយនូវប័ណ្ណព្រំដែនចាស់របស់សាមីខ្លួន។

## ជំពូកទី៣

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ

**ប្រការ ៦.-**

ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តជាប់ព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ អាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ឡាវនៅសាលាខេត្តដែលខ្លួនកំពុងរស់នៅ និងមានលំនៅឋានអចិន្ត្រៃយ៍ពិតប្រាកដ។ ប្រជាពលរដ្ឋខ្មែរម្នាក់អាចកាន់ប័ណ្ណព្រំដែនកម្ពុជា-ឡាវតែមួយគត់។

ការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវជូនប្រជាពលរដ្ឋខ្មែរ ត្រូវធ្វើឡើងតាមយន្តការច្រកចេញចូលតែមួយនៅសាលាខេត្ត ឬទីតាំងផ្សេងៗទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត តាមស្មារតីនៃអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ៧.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវត្រូវបានផ្តល់ជូនប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងខេត្តដែលសាមីខ្លួនស្នើសុំប័ណ្ណព្រំដែន។ ចំពោះកុមារដែលមានអាយុក្រោម ១៥ឆ្នាំ ត្រូវមានសំណើសុំ ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុក ឬម្តាយ ឬអាណាព្យាបាល។

កុមារអាយុក្រោម ១២ឆ្នាំ អាចដាក់បញ្ចូលជាមួយប័ណ្ណព្រំដែនរបស់ឪពុក ឬម្តាយ ឬអាណាព្យាបាលបានដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

កូនដែលមានឈ្មោះក្នុងប័ណ្ណព្រំដែននេះ មិនអនុញ្ញាតឲ្យធ្វើដំណើរដោយឡែកពីអ្នកកាន់ប័ណ្ណព្រំដែនឡើយ។

**ប្រការ ៨.-**

សំណុំឯកសារភ្ជាប់ដើម្បីស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ឡាវ មានដូចខាងក្រោម ៖

១-ពាក្យស្នើសុំប័ណ្ណព្រំដែនចំនួន ០១ច្បាប់ ដោយមានបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំរបស់សាមីខ្លួននៅលើពាក្យស្នើសុំ

២-រូបថតសាមីខ្លួនបច្ចុប្បន្ន ទំហំ ៤ x ៦ "ថតចំពីមុខគ្មានពាក់មួក ឬវ៉ែនតា" ចំនួន ០២សន្លឹក

៣-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតដែលជាច្បាប់ដើម ឬថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

៤-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

**ប្រការ ៩.-**

អ្នកស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ឡាវ ចាំបាច់ត្រូវ ៖

- បង្ហាញមុខដោយផ្ទាល់ជាមួយមន្ត្រីមានសមត្ថកិច្ចនៅសាលាខេត្តដែលសាមីខ្លួនដាក់ពាក្យស្នើសុំប័ណ្ណព្រំដែន ឬទីតាំងផ្សេងទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត
- បំពេញពាក្យស្នើសុំប័ណ្ណព្រំដែនមួយច្បាប់ ដែលមានបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃរបស់សាមីខ្លួន
- ភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬឯកសារថតចម្លងតាមច្បាប់ដើមដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ
- ផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាលើប័ណ្ណព្រំដែននៅចំពោះមុខមន្ត្រីមានសមត្ថកិច្ចផ្តល់ប័ណ្ណព្រំដែន
- បង់ថ្លៃអាករប័ណ្ណព្រំដែនតាមការកំណត់នៃប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទទួលយកបង្កាន់ដៃបង់ប្រាក់សម្រាប់បង្ហាញមន្ត្រីមានសមត្ថកិច្ច នៅពេលទទួលយកប័ណ្ណព្រំដែន។

**ប្រការ ១០.-**

មន្ត្រីមានសមត្ថកិច្ចផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ចាំបាច់ត្រូវ ៖

- ទទួលពាក្យស្នើសុំប័ណ្ណព្រំដែនដែលបានបំពេញត្រឹមត្រូវ និងភ្ជាប់ឯកសារបានគ្រប់គ្រាន់តាមការកំណត់
- ណែនាំឲ្យប្រជាពលរដ្ឋផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាលើប័ណ្ណព្រំដែន ឬបិទរូបថត
- យកភិនភាគ និងស្លាកស្នាមសំគាល់ពិសេស
- វាស់កម្ពស់
- សរសេរបង្កាន់ដៃបង់ប្រាក់ ទទួលប្រាក់កម្រៃសេវាផ្តល់ប័ណ្ណព្រំដែន និងផ្តល់បង្កាន់ដៃបង់ប្រាក់ជូនប្រជាពលរដ្ឋ
- ផ្តល់ប័ណ្ណព្រំដែនជូនដល់ប្រជាពលរដ្ឋទៅតាមពេលវេលាកំណត់។

**ប្រការ ១១.-**

ក្នុងករណីប័ណ្ណព្រំដែនកម្ពុជា-ឡាវត្រូវបានបាត់ដោយមូលហេតុផ្សេងៗ សាមីខ្លួនត្រូវដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងឃុំ សង្កាត់ដែលកើតហេតុការណ៍បាត់ មិនឲ្យលើសពី ៤៨ម៉ោងបន្ទាប់ពីដឹងថាបាត់។

បន្ទាប់ពីបាត់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ សាមីខ្លួនអាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនថ្មីបាន ដោយបំពេញសំណុំឯកសារ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នៃប្រកាសនេះ និងភ្ជាប់មកជាមួយនូវពាក្យបណ្តឹងអំពីការបាត់ប័ណ្ណព្រំដែន ឬកំណត់ហេតុរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងឃុំ សង្កាត់ដែលមានបញ្ជាក់អំពីការបាត់ប័ណ្ណព្រំដែនរបស់សាមីខ្លួន។

**ប្រការ ១២.-**

ក្នុងករណីប័ណ្ណព្រំដែនកម្ពុជា-ឡាវត្រូវបានរហែក ឬលុបអក្សរ ឬខូចទ្រង់ទ្រាយ សាមីខ្លួនអាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនថ្មីបាន ដោយបំពេញសំណុំឯកសារ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នៃប្រកាសនេះ និងភ្ជាប់មកជាមួយនូវប័ណ្ណព្រំដែនដែលត្រូវបានរហែក ឬលុបអក្សរ ឬខូចទ្រង់ទ្រាយនោះ។

**ប្រការ ១៣.-**

ការកំណត់កម្រៃ និងរយៈពេលនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ឡាវជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវអនុលោមទៅតាមប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីមានតម្រូវការកែប្រែកម្រៃ និងរយៈពេលនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ឡាវនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៤.-**

ការគ្រប់គ្រងចំណូល ចំណាយ ការកត់ត្រា និងការផ្តល់ប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូនមន្ត្រី ដែលបំពេញភារកិច្ចផ្ទាល់ក្នុងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ឡាវ និងមន្ត្រីផ្សេងទៀត ត្រូវអនុលោមទៅតាមប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និង



ក្រសួងមហាផ្ទៃ

ហិរញ្ញវត្ថុ ស្ដីពីការផ្ដល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ១៥.-**

ស្ថាប័នមានសមត្ថកិច្ចមានសិទ្ធិបដិសេធមិនផ្ដល់ប័ណ្ណព្រំដែន ដកហូតប័ណ្ណព្រំដែនទុក និងបដិសេធប័ណ្ណព្រំដែនដែលបានផ្ដល់ឲ្យរួចហើយ ក្នុងករណីណាមួយដូចខាងក្រោម៖

- ពិរុទ្ធជន ទណ្ឌិត ឬជនកំពុងមានដីកាបង្គាប់ឲ្យចាប់ខ្លួន
- ជនដែលមានការសម្រេចពីតុលាការហាមឃាត់ការចាកចេញពីព្រះរាជាណាចក្រកម្ពុជា
- ជនដែលមានសំណើពីស្ថាប័នមានសមត្ថកិច្ចសុំមិនឲ្យផ្ដល់ប័ណ្ណព្រំដែន
- ជនដែលបានទទួលប័ណ្ណព្រំដែនដែលបានផ្ដល់ឲ្យខុសពីការប្រកាស ដោយសារការផ្ដល់ព័ត៌មានខុសពីការពិត ឬដោយការក្លែងបន្លំ
- ជនដែលកោសលប់ ឬកែខ្លឹមសារ ឬដូររូបថតនៃប័ណ្ណព្រំដែន
- ជនវិកលចរិត
- អ្នកដែលពុំមានឯកសារគ្រប់គ្រាន់តាមការកំណត់។

ប័ណ្ណព្រំដែនដែលត្រូវបានដកហូតទុក ស្ថាប័នមានសមត្ថកិច្ចត្រូវប្រគល់មកជូនរដ្ឋបាលខេត្ត។

## ជំពូកទី៤

## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ ១៦.-**

ក្រសួងមហាផ្ទៃប្រគល់ភារកិច្ចឲ្យអគ្គនាយកដ្ឋានរដ្ឋបាល ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ឡាវរបស់ខេត្តជាប់ព្រំដែនឡាវ។

រដ្ឋបាលខេត្តត្រូវបង្កើតយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការប្រើប្រាស់ប័ណ្ណព្រំដែនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែអំពីលទ្ធផលការងារផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ជូនមកអគ្គនាយកដ្ឋានរដ្ឋបាលឲ្យបានទៀងទាត់ ដើម្បីបូកសរុបរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៨.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការ

ដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តជាប់ព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

**កន្លែងទទួល ៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ដូចប្រការ ១៨
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៤៣៧ ប្រក

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីប័ណ្ណព្រំដែនកម្ពុជា-ថៃ
- បានឃើញកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិកាវង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- តាមសំណើរបស់អគ្គនាយកដ្ឋានរដ្ឋបាល

## សម្រេច

## ជំពូកទី១

## សមត្ថកិច្ចគ្រប់គ្រង និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

**ប្រការ ១.-**

អភិបាលខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជាជាមួយព្រះរាជាណាចក្រថៃ ត្រូវបានប្រតិភូកម្មអំណាចឱ្យចុះហត្ថលេខាលើប័ណ្ណព្រំដែនកម្ពុជា-ថៃ ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីផ្តល់ជូនប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អភិបាលខេត្តត្រូវដឹកនាំ ចាត់ចែង និងផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរ ស្របទៅតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់ជាធរមាន។

**ប្រការ ២.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវបានផលិត គ្រប់គ្រង ចាត់ចែង និងបែងចែកទៅតាមខេត្តដោយក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ជាសេនាធិការ។

អគ្គនាយកដ្ឋានរដ្ឋបាលជាសេនាធិការឱ្យក្រសួងមហាផ្ទៃនៅក្នុងការរៀបចំទម្រង់បែបបទ និងផ្តល់ការណែនាំបណ្តុះបណ្តាលមន្ត្រីនៅរដ្ឋបាលខេត្ត ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគ្រប់គ្រងការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃ។

អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុជាសេនាធិការឱ្យក្រសួងមហាផ្ទៃនៅក្នុងការផលិត និងរក្សាទុកប័ណ្ណព្រំដែនកម្ពុជា-ថៃឱ្យបានត្រឹមត្រូវ ដោយមានកិច្ចសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល។

## ជំពូកទី២

## អំពីប័ណ្ណព្រំដែនកម្ពុជា-ថៃ

**ប្រការ ៣.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃមានពណ៌ខៀវ និងមានចំនួន ៣២ទំព័រ ដែលមានលក្ខណៈសំគាល់របស់សាមីខ្លួនដូចខាងក្រោម៖

- ឈ្មោះ "នាមត្រកូល និងនាមខ្លួន"

- ភេទ
- លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលេខប័ណ្ណបញ្ជាក់ទីលំនៅ ឬលេខសំបុត្រកំណើត ឬលេខសំបុត្របញ្ជាក់កំណើត ឬលេខសៀវភៅគ្រួសារ
- ថ្ងៃខែឆ្នាំកំណើត
- ទីកន្លែងកំណើត
- កម្ពស់
- មុខរបរ
- អាសយដ្ឋាន
- ភិនភាគសំគាល់ពិសេស
- រូបថត
- ហត្ថលេខា ឬស្នាមផ្តិតមេដៃស្តាំ។

ក្នុងប័ណ្ណព្រំដែនកម្ពុជា-ថៃអាចបញ្ចូលឈ្មោះកូនស្របច្បាប់របស់អ្នកកាន់ប័ណ្ណព្រំដែនបានចំនួន ០២នាក់ ដែលមានអាយុក្រោម ១២ឆ្នាំ ដោយត្រូវកំណត់លក្ខណៈសំគាល់របស់កូនដូចខាងក្រោម៖

- ឈ្មោះ "នាមត្រកូល និងនាមខ្លួន"
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- រូបថត
- លក្ខណៈសំគាល់។

លក្ខណៈសំគាល់ខាងលើនេះ ត្រូវចុះក្នុងប័ណ្ណព្រំដែនជាភាសាខ្មែរ និងភាសាអង់គ្លេស។

**ប្រការ ៤.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃមានសុពលភាពរយៈពេល ០២ឆ្នាំ និងអាចបន្តសុពលភាពបានយ៉ាងយូរ ០២ឆ្នាំ។ ផុតរយៈពេលបន្តសុពលភាពនេះ មិនអាចប្រើប្រាស់បានតទៅទៀតទេ។

**ប្រការ ៥.-**

នៅពេលផុតសុពលភាពប័ណ្ណព្រំដែនកម្ពុជា-ថៃ សាមីខ្លួនអាចស្នើសុំបន្តសុពលភាពប័ណ្ណព្រំដែនបាន ដោយត្រូវបំពេញពាក្យស្នើសុំ និងភ្ជាប់មកជាមួយនូវប័ណ្ណព្រំដែនចាស់របស់សាមីខ្លួន។

## ជំពូកទី៣

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

**ប្រការ ៦.-**

ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ អាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ថៃនៅសាលាខេត្តដែលខ្លួនកំពុងរស់នៅ និងមានលំនៅឋានអចិន្ត្រៃយ៍ពិតប្រាកដ។ ប្រជាពលរដ្ឋខ្មែរម្នាក់អាចកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃតែមួយគត់។

ការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃជូនប្រជាពលរដ្ឋខ្មែរ ត្រូវធ្វើឡើងតាមយន្តការច្រកចេញចូលតែមួយនៅសាលាខេត្ត ឬទីតាំងផ្សេងៗទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត តាមស្មារតីនៃអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ៧.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវបានផ្តល់ជូនប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងខេត្តដែលសាមីខ្លួនស្នើសុំប័ណ្ណព្រំដែន។ ចំពោះកុមារដែលមានអាយុក្រោម ១៥ឆ្នាំ ត្រូវមានសំណើសុំ ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុក ឬម្តាយ ឬអាណាព្យាបាល។

កុមារអាយុក្រោម ១២ឆ្នាំ អាចដាក់បញ្ចូលជាមួយប័ណ្ណព្រំដែនរបស់ឪពុក ឬម្តាយ ឬអាណាព្យាបាលបានដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

កូនដែលមានឈ្មោះក្នុងប័ណ្ណព្រំដែននេះ មិនអនុញ្ញាតឲ្យធ្វើដំណើរដោយឡែកពីម្ចាស់ប័ណ្ណព្រំដែនឡើយ។

**ប្រការ ៨.-**

សំណុំឯកសារភ្ជាប់ដើម្បីស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ថៃមានដូចខាងក្រោម ៖

១-ពាក្យស្នើសុំប័ណ្ណព្រំដែនចំនួន ០១ច្បាប់ ដោយមានបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំរបស់សាមីខ្លួននៅលើពាក្យស្នើសុំ

២-រូបថតសាមីខ្លួនបច្ចុប្បន្ន ទំហំ ៤ x ៦ "ថតចំពីមុខគ្មានពាក់មួក ឬវ៉ែនតា" ចំនួន ០២សន្លឹក

៣-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតដែលជាច្បាប់ដើម ឬថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

៤-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

**ប្រការ ៩.-**

អ្នកស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ថៃ ចាំបាច់ត្រូវ ៖

- បង្ហាញមុខដោយផ្ទាល់ជាមួយមន្ត្រីមានសមត្ថកិច្ចនៅសាលាខេត្តដែលសាមីខ្លួនដាក់ពាក្យស្នើសុំប័ណ្ណព្រំដែន ឬទីតាំងផ្សេងទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត
- បំពេញពាក្យស្នើសុំប័ណ្ណព្រំដែនមួយច្បាប់ ដែលមានបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃរបស់សាមីខ្លួន
- ភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬឯកសារថតចម្លងតាមច្បាប់ដើមដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ
- ផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាលើប័ណ្ណព្រំដែននៅចំពោះមុខមន្ត្រីមានសមត្ថកិច្ចផ្តល់ប័ណ្ណព្រំដែន
- បង់ថ្លៃអាករប័ណ្ណព្រំដែនតាមការកំណត់នៃប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទទួលយកបង្កាន់ដៃបង់ប្រាក់សម្រាប់បង្ហាញមន្ត្រីមានសមត្ថកិច្ច នៅពេលទទួលយកប័ណ្ណព្រំដែន។

**ប្រការ ១០.-**

មន្ត្រីមានសមត្ថកិច្ចផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចាំបាច់ត្រូវ ៖

- ទទួលពាក្យស្នើសុំប័ណ្ណព្រំដែនដែលបានបំពេញត្រឹមត្រូវ និងភ្ជាប់ឯកសារបានគ្រប់គ្រាន់តាមការកំណត់
- ណែនាំឲ្យប្រជាពលរដ្ឋផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាលើប័ណ្ណព្រំដែន ឬបិទរូបថត
- យកភិនភាគ និងស្លាកស្នាមសំគាល់ពិសេស
- វាស់កម្ពស់
- សរសេរបង្កាន់ដៃបង់ប្រាក់ ទទួលប្រាក់កម្រៃសេវាផ្តល់ប័ណ្ណព្រំដែន និងផ្តល់បង្កាន់ដៃបង់ប្រាក់ជូនប្រជាពលរដ្ឋ
- ផ្តល់ប័ណ្ណព្រំដែនជូនដល់ប្រជាពលរដ្ឋទៅតាមពេលវេលាកំណត់។

**ប្រការ ១១.-**

ក្នុងករណីប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវបានបាត់ដោយមូលហេតុផ្សេងៗ សាមីខ្លួនត្រូវដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងឃុំ សង្កាត់ដែលកើតហេតុការណ៍បាត់ មិនឲ្យលើសពី ៤៨ម៉ោងបន្ទាប់ពីដឹងថាបាត់។

បន្ទាប់ពីបាត់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សាមីខ្លួនអាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ថៃថ្មីបាន ដោយបំពេញសំណុំឯកសារ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នៃប្រកាសនេះ និងភ្ជាប់មកជាមួយនូវពាក្យបណ្តឹងអំពីការបាត់ប័ណ្ណព្រំដែន ឬកំណត់ហេតុរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងឃុំ សង្កាត់ដែលមានបញ្ជាក់អំពីការបាត់ប័ណ្ណព្រំដែនរបស់សាមីខ្លួន។

**ប្រការ ១២.-**

ក្នុងករណីប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវបានរហែក ឬលុបអក្សរ ឬខូចទ្រង់ទ្រាយ សាមីខ្លួនអាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនថ្មីបាន ដោយបំពេញសំណុំឯកសារ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នៃប្រកាសនេះ និងភ្ជាប់មកជាមួយនូវប័ណ្ណព្រំដែនកម្ពុជា-ថៃដែលត្រូវបានរហែក ឬលុបអក្សរ ឬខូចទ្រង់ទ្រាយនោះ។

**ប្រការ ១៣.-**

ការកំណត់កម្រៃ និងរយៈពេលនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវអនុលោមទៅតាមប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីមានតម្រូវការកែប្រែកម្រៃ និងរយៈពេលនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៤.-**

ការគ្រប់គ្រងចំណូល ចំណាយ ការគត់ត្រា និងការផ្តល់ប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ក្នុងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ និងមន្ត្រីផ្សេងទៀត ត្រូវអនុលោមទៅតាមប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់ចរិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ១៥.-**

ស្ថាប័នមានសមត្ថកិច្ចមានសិទ្ធិបដិសេធមិនផ្តល់ប័ណ្ណព្រំដែន ដកហូតប័ណ្ណព្រំដែនទុក និងបដិសេធប័ណ្ណព្រំដែនដែលបានផ្តល់ឲ្យរួចហើយ ក្នុងករណីណាមួយដូចខាងក្រោម៖

- ពិរុទ្ធជន ទណ្ឌិត ឬជនកំពុងមានដីកាបង្គាប់ឲ្យចាប់ខ្លួន
- ជនដែលមានការសម្រេចពីតុលាការហាមឃាត់ការចាកចេញពីព្រះរាជាណាចក្រកម្ពុជា
- ជនដែលមានសំណើពីស្ថាប័នមានសមត្ថកិច្ចសុំមិនឲ្យផ្តល់ប័ណ្ណព្រំដែន
- ជនដែលបានទទួលប័ណ្ណព្រំដែនដែលបានផ្តល់ឲ្យខុសពីការប្រកាស ដោយសារការផ្តល់ព័ត៌មានខុសពីការពិត ឬដោយការក្លែងបន្លំ
- ជនដែលកោសលប់ ឬកែខ្លឹមសារ ឬដូររូបថតនៃប័ណ្ណព្រំដែន
- ជនវិកលចរិក
- អ្នកដែលពុំមានឯកសារគ្រប់គ្រាន់តាមការកំណត់។

ប័ណ្ណព្រំដែនដែលត្រូវបានដកហូតទុក ស្ថាប័នមានសមត្ថកិច្ចត្រូវប្រគល់មកជូនរដ្ឋបាលខេត្ត។

## ជំពូកទី៤

## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ ១៦.-**

ក្រសួងមហាផ្ទៃប្រគល់ភារកិច្ចឲ្យអគ្គនាយកដ្ឋានរដ្ឋបាល ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃរបស់ខេត្តជាប់ព្រំដែនថៃ។

រដ្ឋបាលខេត្តត្រូវបង្កើតយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការប្រើប្រាស់ប័ណ្ណព្រំដែនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែអំពីលទ្ធផលការងារផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនមកអគ្គនាយកដ្ឋានរដ្ឋបាលឲ្យបានទៀងទាត់ ដើម្បីបូកសរុបរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៧.-**

ត្រូវបាននិរាករណ៍ប្រកាស និងសារាចរណែនាំ ដូចខាងក្រោម៖

- ប្រកាសលេខ ១២៤២ ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធីនៃការផ្តល់ប័ណ្ណឆ្លងដែននៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ
- សារាចរណែនាំលេខ ០០២ សរ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្តល់ប័ណ្ណឆ្លងដែនជូនប្រជាពលរដ្ឋខ្មែរ និងការគ្រប់គ្រងការឆ្លងកាត់ព្រំដែន។

**ប្រការ ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៩.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ដូចប្រការ ១៩
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៧៥ ប្រក.កសក

# ប្រកាស
## ស្តីពី
## ស្លាកសញ្ញាព័ត៌មានបញ្ជាក់លើសំបកវេចខ្ចប់ពូជដំណាំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់នូវស្លាកសញ្ញាព័ត៌មានពូជដំណាំ ដែលត្រូវបង្ហាញនៅលើសំបកវេចខ្ចប់ពូជដំណាំគ្រប់ប្រភេទ ដែលធ្វើអាជីវកម្ម ឬធ្វើចរាចរណ៍លើទីផ្សារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅធានានូវព័ត៌មានស្តីពីពូជដំណាំគ្រប់ប្រភេទ ដែលត្រូវបញ្ជាក់នៅលើសំបកវេចខ្ចប់ពូជដំណាំ ដែលធ្វើចរាចរណ៍លើទីផ្សារក្នុងគោលបំណងធ្វើអាជីវកម្ម ឬធ្វើប្រតិបត្តិការក្រៅគោលបំណងអាជីវកម្ម ដើម្បីបង្កើនការយល់ដឹងអំពីព័ត៌មានបច្ចេកទេស និងរបៀបប្រើប្រាស់ពូជដំណាំ បង្កើនភាពប្រុងប្រយ័ត្នចំពោះពូជដំណាំក្លែងគុណភាពឬមានប្រភពមិនស្របច្បាប់ ការពារផលប្រយោជន៍របស់អាជីវករពូជដំណាំ ព្រមទាំងកសិករ និងអ្នកប្រើប្រាស់ពូជដំណាំផ្សេងទៀត នៅក្នុងផលិតកម្មកសិកម្ម។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះប្រភេទពូជដំណាំគ្រប់ប្រភេទ រួមមានប្រភេទពូជដែលមានស្រាប់ និងពូជថ្មីនៃដំណាំ ព្រមទាំងរាល់សកម្មភាពដែលពាក់ព័ន្ធនឹងផលិតកម្មពូជដំណាំគ្រប់ប្រភេទ ក្នុងគោលបំណងឬក្រៅគោលបំណងអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រកាសនេះមិនគ្របដណ្តប់ ចំពោះពូជដំណាំដែលស្ថិតនៅក្រោមរូបភាពប្រើប្រាស់ជាក់លាក់ក្នុងផលិតកម្មកសិកម្មជាលក្ខណៈគ្រួសារ និងមិនធ្វើចរាចរណ៍លើទីផ្សារ។

## ជំពូកទី២

## សំបកវេចខ្ចប់ពូជដំណាំ

### ផ្នែកទី១

### ការតម្រូវស្លាកសញ្ញាព័ត៌មានស្តីពីពូជដំណាំ

**ប្រការ ៤.-**

ពូជដំណាំគ្រប់ប្រភេទ ដែលធ្វើអាជីវកម្មគ្រប់រូបភាព និងធ្វើចរាចរណ៍លើទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវរៀបចំច្រកក្នុងសំបកវេចខ្ចប់ឬសម្ភារវេចខ្ចប់ ដែលផលិតដោយវត្ថុធាតុធន់នឹងភាពហែកធ្លុះធ្លាយ ធន់នឹងធាតុអាកាសមិនងាយថយចុះគុណភាព ព្រមទាំងសម្រួលដល់ការដឹកជញ្ជូន ការធ្វើសន្និធិ និងការប្រើប្រាស់។

សំបកវេចខ្ចប់ ពូជដំណាំគ្រប់ប្រភេទ ត្រូវមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ដែលអាចបោះពុម្ពឬបិទឬភ្ជាប់នៅលើសំបកវេចខ្ចប់នោះ។

ការវេចខ្ចប់ជាថ្មីនូវពូជដំណាំគ្រប់ប្រភេទ សម្រាប់បម្រើតាមតម្រូវការទីផ្សារ ត្រូវធានាដូចគ្នានូវសំបកវេចខ្ចប់ ដូចបានកំណត់លក្ខខណ្ឌនៅក្នុងប្រកាសនេះ និងត្រូវរក្សាស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ជាចាំបាច់សម្រាប់អ្នកប្រើប្រាស់។

**ប្រការ ៥.-**

ស្លាកសញ្ញាព័ត៌មាន គឺជាបទប្បញ្ញត្តិដែលបានបោះពុម្ពនៅលើសំបកវេចខ្ចប់ពូជដំណាំ ឬបានកំណត់នៅក្នុងបរិយាយប័ណ្ណព័ត៌មានសម្រាប់ប្រភេទពូជដំណាំណាមួយ នៅក្នុងប្រតិបត្តិការផលិតនិងកែច្នៃ ការវេចខ្ចប់ និងការវេចខ្ចប់ជាថ្មី ដើម្បីធានាគុណភាព និងសុវត្ថិភាពនៃពូជដំណាំសម្រាប់អាជីវករនិងអ្នកទិញយកទៅប្រើប្រាស់។

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ត្រូវភ្ជាប់ជាមួយពាក្យស្នើសុំនូវគំរូស្លាកសញ្ញាព័ត៌មានពូជដំណាំនោះតាមយថាប្រភេទនីមួយៗ សម្រាប់ការពិនិត្យនិងវាយតម្លៃដោយអគ្គនាយកដ្ឋានកសិកម្ម ស្របតាមការតម្រូវលក្ខខណ្ឌសម្រាប់ស្លាកសញ្ញាព័ត៌មានពូជដំណាំ។

**ប្រការ ៦.-**

ការតម្រូវលក្ខខណ្ឌសម្រាប់ស្លាកសញ្ញាព័ត៌មានពូជដំណាំ ត្រូវបានកំណត់ដូចខាងក្រោម៖

១-ព័ត៌មាននៅលើស្លាកសញ្ញា ត្រូវតែមានជាភាសាខ្មែរ ងាយអាន ងាយយល់ និងមិនងាយរលុប។

២-ស្លាកសញ្ញាព័ត៌មានអាចត្រូវបានរចនាទម្រង់ស្របតាមប្រភេទនិងទំហំសំបកវេចខ្ចប់ និងប្រភេទពូជដំណាំនីមួយៗ ដោយប្រមូលផ្ដុំនូវព័ត៌មានសំខាន់ៗ សម្រាប់អ្នកប្រើប្រាស់អានដោយយកចិត្តទុកដាក់ នៅមុនពេលសម្រេចចិត្តទិញពូជដំណាំនោះយកទៅធ្វើអាជីវកម្ម ឬប្រើប្រាស់។

៣-ចំពោះសំបកវេចខ្ចប់ដែលមានទំហំតូច ស្លាកសញ្ញាព័ត៌មានអាចបោះពុម្ពតែព័ត៌មានសំខាន់ៗនៃពូជដំណាំប៉ុណ្ណោះ។ ចំពោះអត្ថបទណែនាំស្ដីពីរបៀបប្រើប្រាស់ពូជដំណាំ និងព័ត៌មានផ្សេងទៀតអាចបោះពុម្ពឬរៀបចំឱ្យមានបរិយាយប័ណ្ណព័ត៌មានពូជដំណាំដោយឡែក។

៤-ស្លាកសញ្ញាព័ត៌មានពូជដំណាំដែលត្រូវបោះពុម្ពនៅលើសំបកវេចខ្ចប់ ឬនៅក្នុងបរិយាយប័ណ្ណព័ត៌មានពូជដំណាំត្រូវមានព័ត៌មានអប្បបរមា ដូចខាងក្រោម៖

ក-នៅផ្នែកខាងមុខឬផ្នែកសំខាន់នៃសំបកវេចខ្ចប់៖

-ឈ្មោះដំណាំ៖ ឈ្មោះវិទ្យាសាស្ត្រ ឈ្មោះពាណិជ្ជកម្ម ឈ្មោះក្នុងស្រុក

-ប្រភេទពូជ

-ចំណាត់ថ្នាក់

-ពាណិជ្ជសញ្ញា

-លេខវិញ្ញាបនបត្របញ្ជាក់គុណភាព

-អត្រាសំណើម

-អត្រាដំណុះ

-ភាពសុទ្ធនៃពូជដំណាំ

-កាលបរិច្ឆេទផលិតនិងវេចខ្ចប់ និងកាលបរិច្ឆេទផុតសុពលភាព

-ប្រភេទថ្នាំកសិកម្មដែលប្រើសម្រាប់ការពារ

-របៀបប្រើប្រាស់។

ខ-ផ្នែកខាងខ្នងឬផ្នែកបន្ទាប់បន្សំនៃសំបកវេចខ្ចប់៖

-ឈ្មោះ និងអាសយដ្ឋាន ក្រុមហ៊ុន/ប្រទេស ប្រភពដើមផលិត កែច្នៃពូជដំណាំ
-ឈ្មោះ និងអាសយដ្ឋាន ក្រុមហ៊ុន/ប្រទេស នាំចូលនិងចរាចរណ៍លើទីផ្សារ
-លេខឡូតិ៍
-បរិមាណពូជដំណាំ (ក្រាមឬគីឡូក្រាមឬចំនួន) ។

## ផ្នែកទី២
## រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព

**ប្រការ ៧.-**

អនុញ្ញាតឱ្យបង្កើត និងប្រើប្រាស់រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព សម្រាប់បិទឬភ្ជាប់នៅលើសំបកវេចខ្ចប់ផលិតផលពូជដំណាំដែលអនុញ្ញាតឱ្យធ្វើអាជីវកម្ម ឬចរាចរណ៍លើទីផ្សារ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាពត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៨.-**

អគ្គនាយកដ្ឋានកសិកម្ម ត្រូវគ្រប់គ្រងការប្រើប្រាស់រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាពដែលត្រូវបិទឬភ្ជាប់លើសំបកវេចខ្ចប់ផលិតផលពូជដំណាំគ្រប់ប្រភេទ ដែលបានត្រួតពិនិត្យគុណភាពរួច និងបានផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំជាធរមាន។

**ប្រការ ៩.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើអាជីវកម្មផលិតកែច្នៃ ឬពង្រីកពូជដំណាំ និងធ្វើការនាំចូលពូជដំណាំ ត្រូវបានផ្តល់រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព ដើម្បីបិទឬភ្ជាប់នៅលើសំបកវេចខ្ចប់ផលិតផលពូជដំណាំរបស់ខ្លួន នៅមុនពេលអនុញ្ញាតឱ្យធ្វើចរាចរណ៍លើទីផ្សារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ផលិតផលពូជដំណាំគ្រប់ប្រភេទ ដែលបានទទួលវិញ្ញាបនបត្របញ្ជាក់គុណភាពស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំត្រូវមានរូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាពបិទឬភ្ជាប់នៅលើសំបកវេចខ្ចប់ជាចាំបាច់ ដើម្បីសម្គាល់នូវផលិតផលពូជដំណាំ ដែលបានត្រួតពិនិត្យគុណភាពរួច និងត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្ម ឬធ្វើចរាចរណ៍លើទីផ្សារស្របតាមច្បាប់ជាធរមាន។

## ជំពូកទី៣
## ទោសប្បញ្ញត្តិ

**ប្រការ ១០.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលធ្វើអាជីវកម្មឬធ្វើចរាចរណ៍លើទីផ្សារពូជដំណាំគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលខុសត្រូវចំពោះគុណភាពពូជដំណាំរបស់ខ្លួន ដែលដាក់តាំងលក់ឬធ្វើសន្និធិសម្រាប់លក់ ដែលតម្រូវឱ្យមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ និងត្រូវមានរូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព បិទឬភ្ជាប់

នៅលើសំបកវេចខ្ចប់ពូជដំណាំនោះជាចាំបាច់ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងប្រកាសនេះជាធរមាន។

**ប្រការ ១១.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មជាក់លាក់ ដោយអនុលោមតាមទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

## ជំពូកទី៤

## អវសានប្បញ្ញត្ត

**ប្រការ ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៣.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី...០៧...ខែ...កក្កដា.....ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងពាណិជ្ជកម្ម
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ**



រូប "ព្រះមេ" ជារូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី